Trial SC (8)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

12 May/2021

17/4

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**
**សភាព្រហ្មទណ្ឌ**
សំណុំរឿងលេខ ៧៩
ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១
**សាលដីកា**
**លេខ: ៩៤** ព្រទ.ក្រIII(ទ.ណ)
ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦/០៧/២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹក ថ្ងៃចន្ទ ៦កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០២១ ដែលមានសមាសភាពដូចខាងក្រោមៈ

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted] ជាក្រឡាបញ្ជី

ដើម្បីពិភាក្សាដេញដោលលើបណ្តឹងឧទ្ធរណ៍លើសំណុំរឿងលេខ ៧៩ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមានៈ

✓ -**ជនជាប់ចោទ៖** ឈ្មោះ [redacted] **សាវេត** ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាបស ឃុំស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ទីលំនៅមុនពេលចាប់ខ្លួននៅ[redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ឆាង (ស) ម្តាយ ឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] លុច (រ) មានកូនចំនួន ០១នាក់ ជានីតិជន ។ (ក្នុងឃុំ) (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩០៨ ត.ព្រ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ។

-**ពិរុទ្ធជន** ឈ្មោះ [redacted] **លុច** ភេទប្រុស កើតឆ្នាំ១៩៧៥ ជាតិខ្មែរ កើតនៅភូមិតាបស ឃុំស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិ[redacted]ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] (ស) ម្តាយ ឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] សាវេត (រ) មានកូនចំនួន ០៣នាក់ ជានីតិជន ។ (គេចខ្លួន)

ដីការបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៦ ត.ព្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ។

**<u>ត្រូវជាប់ចោទពីបទ</u>៖ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅ[redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស[redacted] តាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

មានលោក [redacted] **ស៊ីថិន** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ ។



Scanned with CamScanner

<u>**អង្គហេតុមានដូចតទៅ**</u>

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] សាវេត និងឈ្មោ [redacted] លុច បានប្រព្រឹត្តបទល្មើសកាប់ទន្ទ្រានរានយកដីព្រៃ និងបរបាញ់សត្វព្រៃដោយខុសច្បាប់ក្នុងតំបន់ការពារ ហើយបន្ត្រីសមត្ថកិច្ចបានធ្វើការណែនាំ និងអប់រំជាច្រើនលើកច្រើនសាររួចមកហើយ តែជនខាងលើនេះនៅតែប្រព្រឹត្តដដែល ។

**ឯកសារពាក់ព័ន្ធ:**

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១២៨៨ ជ.ស.ព ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ ៣០១៤/២០២០ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ ។

IV.<u>**សេចក្តីសម្រេចរបស់សាលាដំបូងខេត្តព្រះវិហារ**</u>

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ១២៣ "ខ" ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១./ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **សាវេត** ភេទស្រី អាយុ៤៤ឆ្នាំ (សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅ [redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **លុច** ភេទប្រុស កើតឆ្នាំ១៩៧៥ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ឆ្នាំ ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅ [redacted] ស្រុកសង្គមថ្មី ខេត្តព្រះវិហារ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

២./វត្ថុចាប់យករួមមានៈ គោយន្តកន្ត្រៃ គ្មានម៉ាកចំនួន ០១គ្រឿង តាមកំណត់ហេតុទទួលវត្ថុតាំងលេខ ២៤/២០២០ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តព្រះវិហារ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ចំពោះ មុខជនជាប់ចោទឈ្មោះ [redacted] **សាវេត** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **លុច** បើភាគីមិនសុខចិត្តនឹងសេចក្តីសម្រេចនេះមានសិទ្ធិប្តឹងទាស់, ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**-បានឃើញ:** ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **សាវេត** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៣ (ខ) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចៈ **ទាំងមូលនៃសេចក្តីសម្រេច** ។

**នាពេលពិភាក្សាដេញដោល**

**ចៅក្រមរបាយការណ៍ អានរបាយការណ៍រឿង**

-ជនជាប់ចោទឈ្មោះ [redacted] **សាវេត** បានឆ្លើយថាៈ ខ្លួនសូមប្តឹងឧទ្ធរណ៍តែលើចំណុចទី១ ដែលផ្តន្ទាទោសខ្លួន ដាក់ពន្ធនាគារ ៥ឆ្នាំ ដើម្បីសុំឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោស។ ខ្លួនបានកាប់ដីព្រៃតាំងពីឆ្នាំ ២០១០ ហើយបានដាំដំណាំ។ លោក ញឹម បានប្រាប់ថាចាំដូរដីផ្សេងឲ្យ ។ នៅឆ្នាំ ២០១០ មេឃុំប្រជុំថាដីព្រៃជាដីសហគមន៍ ។ គេមកចាប់ខ្លួននៅកន្លែងដកដំឡូង ។ ខ្លួនទទួលស្គាល់ថាបានកាប់ដីព្រៃមែន ដោយសារឃើញមានគេកាប់អ៊ីៗ ។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted]ញឹម (ជាអនុប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ) បានឆ្លើយបំភ្លឺថា: កន្លងមកឈ្មោះ [redacted] សាវេត និង [redacted] លុច បានកាប់ព្រៃជាច្រើនមកហើយ នៅទីតាំងផ្សេង ប៉ុន្តែយើងមិនបានរករឿងគាត់ទេ ទុកឲ្យគាត់ធ្វើស្រែ ។ ក្រោយមកគាត់កាប់ព្រៃបន្តទៀតជាប្រភេទព្រៃអតិរក្ស ព្រៃពាក់កណ្ដាលស្រោង ហើយគាត់កាប់មុនគេ មិនមែនកាប់តាមគេទេ ។ យើងបានឡើង GPS វាស់ឃើញដីព្រៃដែលគាប់កាប់មានទំហំ ៥៣.៥០ហិកតា ។ ការចុះបង្ក្រាប មានការសហការគ្នារវាងកងរាជអាវុធហត្ថ ជាមួយមន្ត្រីឧទ្យានុរក្ស ។ ខាងអាវុធហត្ថឃាត់ខ្លួនឈ្មោះ [redacted] សាវេត ហើយយើងកំពុងសួរឈ្មោះ ទា លុច ពេលគាត់ដឹងថាឃាត់ខ្លួនប្រពន្ធគាត់ ឈ្មោះ [redacted] លុច ក៏បានរត់គេចខ្លួនបាត់ ។ ចំពោះដីរបស់គាត់ទំហំ ៦ហិកតានោះ យើងមិនបានរករឿងគាត់ទេ គឺយើងរករឿងគាត់ដោយសារតែគាត់បានទៅកាប់ព្រៃថ្មីទៀត ។ ក្រោយពីបានឃាត់ខ្លួនជនជាប់ចោទ យើងក៏បានរាយការណ៍ជូនលោកព្រះរាជអាជ្ញាខេត្ត ។ ដីទំហំ ៥៣.៥០ហិកតា គឺគាត់និងប្ដីបានប្រើឈ្មោះយន្តដើម្បីកាប់រាន ហើយមិនមានបូកឬរួមជាមួយដីអ្នកផ្សេងទេ ។

-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទបានឆ្លើយថា ពិតជាបានកាប់ដីព្រៃមែន តែមានតែទំហំ ៦ហិកតាទេ តាំងពីឆ្នាំ ២០១០មក ។ ប៉ុន្តែខាងមន្ត្រីជំនាញបានបំភ្លឺថា ចំពោះដី ៦ហិកតានោះ គឺសមត្ថកិច្ចមិនប្ដឹងលើដីនោះទេ តាមការចុច GPS ឃើញដីដែលជនជាប់ចោទបានបំពានមានទំហំ ៥៣.៥០ហិកតា ។ ជនជាប់ចោទពិតជាបានធ្វើការកាប់គាស់រុករាន ដីព្រៃ ប្រាកដមែន ។ ការផ្ដន្ទាទោសរបស់សាលាដំបូង មានភាពសមល្មម ត្រឹមត្រូវហើយ តំណាងអយ្យការស្នើសូមតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនបានកាប់គាស់ដីតាំងពីឆ្នាំ ២០១០ និងបានដាំដំណាំនិងអាស្រ័យផលលើដីទំហំ ៦ហិកតា យូរមកហើយ ។ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០ គាត់កំពុងដាំបាយប្ដីរៀបចំដំឡូងយកទៅលក់ផ្សារ ការចាប់ឃាត់ខ្លួននៅពេលដាំបាយ ហើយទើបនាំទៅចតនៅលើដី ។ ចំពោះដីទំហំ ៥៣.៥០ហិកតា គឺកូនក្ដីខ្លួនពុំមានលទ្ធភាពកាប់ទេ គ្មានលទ្ធភាពរកកម្មករកាប់ទេ ។ ការលើកឡើងថា មានរណារយន្ត មិនត្រឹមត្រូវទេ ។ ចំពោះការដាក់ទណ្ឌកម្មរបស់សាលាដំបូងមានភាពធ្ងន់ធ្ងរណាស់ចំពោះកូនក្ដីខ្លួន ស្នើសូមក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួនត្រឹម ២ឆ្នាំ ដើម្បីបានទៅមើលថែកូន ។ ឈ្មោះ [redacted] លុច មិនមែនជាប្ដីរបស់កូនក្ដីខ្លួនទេ គ្រាន់តែជាសង្សារ ។

-ជនជាប់ចោទឈ្មោះ [redacted] **សាវេត** បានធ្វើសំណូមពរចុងក្រោយថា៖ ស្នើសូមតុលាការជួយបន្ធូរបន្ថយទោសខ្លួនត្រឹម ២ឆ្នាំ ។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សាវេត**

ក្រោយពីបានស្ដាប់ចម្លើយសាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យកស្ដុតាងក្នុងសំណុំរឿងហើយ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

## យល់ឃើញថា

១-ពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **សាវេត** ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១២៣(ខ) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុច: **ទាំងមូលនៃសេចក្ដីសម្រេច** បានធ្វើឡើងតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន



Scanned with CamScanner

យោងតាមបញ្ញត្តិ មាត្រា ៣៧៥ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា៣៦៨ មាត្រា ៣៧២ មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ ។

២-តាមចម្លើយរបស់ឈ្មោះ [redacted] **សាវេត** បានឆ្លើយសារភាពថាៈ ខ្លួនពិតជាបានកាប់ដីព្រៃមែន ដោយមានទំហំ ៦ ហិកតា ប៉ុណ្ណោះ ។ ចម្លើយនេះមិនទាន់អាចឲ្យតុលាការជឿជាក់បានទេ ពីព្រោះថា តាមការបំភ្លឺរបស់សាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ថា សមត្ថកិច្ចមិនបានរកឃើញជនជាប់ចោទចំពោះដីទំហំ ៦ហិកតានេះទេ ប៉ុន្តែគឺបានរកឃើញចំពោះការកាប់ដីព្រៃបន្ថែមទៀតដែលមានទំហំដល់ទៅ ៥៣.៥០ហិកតា ។

សំអាងហេតុរបស់សាលាដំបូងខេត្តព្រះវិហារ មានលក្ខណៈសមរម្យហើយ សាលាឧទ្ធរណ៍ឯកភាពតាមសំអាងហេតុនោះដោយពុំចាំបាច់លើកយកសំអាងហេតុថ្មីមកបន្ថែមទៀតទេ ។

៣-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ដែលបានស្នើសុំឲ្យតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណារួចហើយ ។

៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ និងសំណូមពរចុងក្រោយរបស់ជនជាប់ចោទដែលបានស្នើសុំឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសលើជនជាប់ចោទមកត្រឹម ២ឆ្នាំនោះ ក្រុមប្រឹក្សាជំនុំជម្រះមិនទទួលពិចារណាទេ ដោយហេតុថា ជនជាប់ចោទមានចរិតរឹងរូសមិនស្តាប់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចដែលបានចុះទៅណែនាំជាច្រើនដង ហើយនៅតែមិនព្រមបញ្ឈប់អំពើកាប់រានដីព្រៃ រហូតត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន ម្យ៉ាងទៀតការសម្រេចផ្តន្ទាទោសជនជាប់ចោទរបស់សាលាដំបូងខេត្តព្រះវិហារ ត្រឹមកម្រិតអប្បបរមានៃទោសហើយ ។

៥-សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ១២៣(ខ) ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ មានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាជំនុំជម្រះនៃសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **សាវេត** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៣(ខ) ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល ។

៣-សាលដីកានេះ បានប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១៤កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **សាវេត** ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted] [redacted] [redacted]



Scanned with CamScanner